ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# បទបញ្ជាផ្ទៃក្នុង

# នៃ

# សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

អនុម័តដោយ គណៈកម្មាធិការប្រតិបត្តិ នៃ សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

ក្នុងសម័យប្រជុំលើកទី១ ថ្ងៃទី 28 ខែ 12 ឆ្នាំ ២០១៥

# បទបញ្ជាផ្ទៃក្នុង
## សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

- យោងតាមលក្ខន្តិកៈរបស់ សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា **ស.អ.ល.ក** ដែលអនុម័តដោយមហាសន្និបាតលើកទី១ នៅថ្ងៃទី១០ ខែ កញ្ញា ឆ្នាំ ២០១៥
- យោងមតិសម្រេចរបស់ប្រធានគណៈកម្មាធិការ នៃ សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា **ស.អ.ល.ក** សម័យប្រជុំ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥

គណៈកម្មាធិការប្រតិបត្តិសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា បានសម្រេចរៀបចំ និងកំណត់បទបញ្ជាផ្ទៃក្នុងសម្រាប់សមាគមដូចខាងក្រោម៖

## ជំពូកទី១
## ទីស្នាក់ការរបស់សមាគម

**ប្រការ ១**.—

អាសយដ្ឋាន អាគារលេខ ៨៥-៨៨,មហាវិថី គីមអ៊ីលស៊ុង(២៨៩), សង្កាត់បឹងកក់២, ខណ្ឌទួលគោក រាជធានីភ្នំពេញ។ សមាគមអាចផ្លាស់ប្តូរទីស្នាក់ការកណ្តាល បានតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការប្រតិបត្តិ។ ដោយឡែកទីស្នាក់ការរបស់សមាគមអាណត្តិទី១ ប្រធានសមាគមអាណត្តិទី១ ជាអ្នកកំណត់ និងទទួលខុសត្រូវទាំងស្រុងចំពោះរាល់ការចំណាយសម្រាប់បង្កើតការិយាល័យកណ្តាល និងចំណាយលើសេវាកម្មផ្សេងៗ។ លុះកណាសមាគមមានដំណើរការរលូនរួចហើយ នោះប្រធានសមាគមអាណត្តិទី១ នឹងធ្វើការទូរទាត់រាល់ការចំណាយផ្សេងៗវិញ។

## ជំពូកទី២
## អំពីសិទ្ធិ និងភាតព្វកិច្ចរបស់សមាជិកភាព

**ប្រការ ២**.—

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានធុរកិច្ចពាក់ព័ន្ធនឹងអាជីវកម្មអភិវឌ្ឍន៍លំនៅឋាន ដែលមានបំណងចូលជាសមាជិក ស.អ.ល.ក ត្រូវដាក់ពាក្យស្នើសុំចូលជាសមាជិកទៅ គណៈកម្មាធិការប្រតិបត្តិ ស.អ.ល.ក ។

**ប្រការ ៣**.—

គណៈកម្មាធិការ និងសមាជិក-សមាជិកា នៃ ស.អ.ល.ក ត្រូវអនុវត្តសេចក្តីសម្រេចរបស់ថ្នាក់ដឹកនាំ និង មានស្មារតីទទួលខុសត្រូវរួបរួមគ្នា និងចូលរួមចំណែកក្នុងសកម្មភាពជាប្រយោជន៍ដល់ ស.អ.ល.ក ។

**ប្រការ ៤.—**

សមាជិកសមាគមទាំងអស់មានសិទ្ធិឈរឈ្មោះ ឱ្យអង្គមហាសន្និបាតបោះឆ្នោតជ្រើសរើសជាប្រធាន អនុប្រធាន អគ្គលេខាធិការ និងប្រធាន ឬអនុប្រធានក្នុងគណៈកម្មាធិការផ្សេងៗរបស់សមាគម។

**ប្រការ ៥.—**

សមាជិកដែលត្រូវបានជាប់ឆ្នោតជាប្រធានសមាគម ត្រូវមានលទ្ធភាព សមត្ថភាព និងការទទួលខុសត្រូវទាំងស្រុងរាល់កិច្ចការ ដំណើរការរបស់សមាគមឱ្យបានល្អប្រសើរ។

**ប្រការ ៦.—**

សមាជិកសមាគមនីមួយៗ មានសិទ្ធិចាត់តាំងបុគ្គលិករបស់ខ្លួនចូលរួមប្រជុំការងារនៅពេលណាដែលខ្លួនអវត្តមាន តែត្រូវមានលិខិតបញ្ជាក់ពីមូលហេតុ និងមានលិខិតចាត់តាំងអ្នកតំណាងដែលមានសិទ្ធិសម្រេចការងារបានជាលាយល័ក្ខអក្សរផ្ញើរជូនប្រធានសមាគម។

**ប្រការ ៧.—**

សមាជិកសមាគមនីមួយៗ មានកាតព្វកិច្ចបង់ភាគទានប្រចាំឆ្នាំ សម្រាប់ទ្រទ្រង់ដំណើរការងារ និងការប្រព្រឹត្តិទៅ របស់ ស.អ.ល.ក ។ សមាជិកត្រូវបង់ភាគទាន សម្រាប់រយៈពេលមួយឆ្នាំម្តង គឺនៅដើមខែមករា នៃឆ្នាំនីមួយៗ។ ដ៏របណាសមាជិកបានអាក់ខានបង់ភាគទាន ដោយពុំមានមូលហេតុបញ្ជាក់នោះ ចាត់ទុកថាសមាជិកនោះលាលែងចេញពីសមាជិករបស់សមាគមដោយស្វ័យប្រវត្តិ។ ក្នុងករណីសមាជិកនោះ ចង់ចូលជាសមាជិករបស់ ស.អ.ល.ក ឡើងវិញ គឺ ត្រូវបង់ភាគទាន ដែលខកខាន តាមពេលវេលាជាក់ស្តែង នៃការខកខាននោះ ជូនស.អ.ល.ក។ ពេលនោះភាពស្របច្បាប់របស់សមាជិក នឹងមានសុពលភាពឡើងវិញដោយស្វ័យប្រវត្តិ។

**ប្រការ ៨.—**

សមាជិកសមាគមនីមួយៗ មានសិទ្ធិចូលរួមធ្វើការផ្សព្វផ្សាយដល់ក្រុមហ៊ុននានា ដែលមានសកម្មភាពដូចគ្នា ដើម្បីឱ្យក្រុមហ៊ុនទាំងនោះ ទទួលបានព័ត៌មានអំពីអត្ថប្រយោជន៍ក្នុងការដែលចូល ជាសមាជិករបស់ ស.អ.ល.ក ដោយមិនគិតថ្លៃឈ្នួល និងគេងចំណេញពីសមាគមដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនឡើយ។

**ប្រការ ៩.—**

សមាជិកសមាគមអាចធ្វើសិក្ខាសាលា ឬផ្សព្វផ្សាយផលិតផល ឬសេវារបស់ក្រុមហ៊ុនខ្លួនតាមរយៈសមាគមដោយមានការស្នើសុំ និងអនុញ្ញាតពីប្រធានសមាគម។

**ប្រការ ១០.—**

សមាជិករបស់សមាគមទាំងអស់ មានសិទ្ធិផ្តល់ព័ត៌មានមកសមាគម ស្តីពីគម្រោងអភិវឌ្ឍន៍ថ្មីៗ របស់ក្រុមហ៊ុនខ្លួន និងការស្វែងរកដៃគូវិនិយោគ ឬបណ្តាក់ទុនក្នុងការធ្វើជំនួញ ដើម្បីឱ្យសមាគមជួយធ្វើការផ្សព្វផ្សាយអំពីតម្រូវការ និងគម្រោងទាំងនោះដោយឥតគិតថ្លៃ។

**ប្រការ ១១.—**

សមាជិកសមាគមនីមួយៗ អាចស្នើសុំអន្តរាគមន៍ពីសមាគមជួយសម្របសម្រួល ប្រឹក្សាយោបល់ ដោះស្រាយទំនាស់ វិវាទ និងភាពរាំងស្ទះផ្សេងៗ ជាមួយសមាជិកដូចគ្នា ឬស្ថាប័នរដ្ឋនានា ឬស្ថាប័នផ្សេងៗ ។

## ជំពូកទី៣
## ការជ្រើសរើស និងតែងតាំង គណៈកម្មាធិការប្រតិបត្តិ

**ប្រការ ១២.—**

គណៈកម្មាធិការប្រតិបត្តិរបស់សមាគមត្រូវធ្វើការជ្រើសរើស និងចាត់តាំងដោយមហាសន្និបាតរបស់សមាគម សម្រាប់អាណត្តិនីមួយៗ។

**ប្រការ ១៣.—**

ប្រធាន អនុប្រធាន អគ្គលេខាធិការ និង សមាជិក នៃ ស.អ.ល.ក ត្រូវបំពេញការងារដោយអនុលោមតាមលក្ខន្តិកៈ ស.អ.ល.ក ។

**ប្រការ ១៤.—**

រាល់សេចក្តីសម្រេចរបស់គណៈកម្មាធិការប្រតិបត្តិ ត្រូវធ្វើឡើងដោយសំឡេងភាគច្រើនដាច់ខាត ៥០ ភាគរយបូក១នៃសមាជិកមានវត្តមាន ។ រាល់ការប្រជុំនីមួយៗ ត្រូវមានកូរ៉ុម ពីរភាគបី នៃសមាជិក ទាំងអស់ របស់ ស.អ.ល.ក ។

**ប្រការ ១៥.—**

គណៈកម្មាធិការប្រតិបត្តិសមាគមត្រូវធ្វើការប្រជុំជ្រើសរើស និងតែងតាំងសមាជិករបស់ខ្លួនដើម្បីទទួលបន្ទុកតាមផ្នែកនីមួយៗរបស់សមាគម ។ សមាសភាពនេះត្រូវមានការបោះឆ្នោតគាំទ្រដោយសម្លេងភាគច្រើនដាច់ខាត របស់សមាជិកគណៈកម្មាធិការប្រតិបត្តិរបស់សមាគម។

**ប្រការ ១៦**.—

គណៈកម្មាធិការប្រតិបត្តិ របស់ ស.អ.ល.ក មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

- ប្រធាន
- អនុប្រធាន
- អគ្គលេខាធិការ
- ផ្នែកអប់រំ បណ្តុះបណ្តាល និងស្រាវជ្រាវ
- ផ្នែកទំនាក់ទំនងជាតិ និងអន្តរជាតិ
- ផ្នែកច្បាប់
- ផ្នែកហេរញ្ញិក
- លេខាធិការ និងរដ្ឋបាល

**ប្រការ ១៧**.—

នៅពេលមានសមាជិកណាត្រូវបានបាត់បង់សមាជិកភាព ឬ ដកហូតពីមុខតំណែងគណៈកម្មាធិការប្រតិបត្តិសមាគម ត្រូវធ្វើការប្រជុំជាបន្ទាន់ និងធ្វើការបោះឆ្នោតជ្រើសរើសសមាជិកថ្មីមកជំនួសវិញក្រោយរយៈពេលមួយសប្តាហ៍។

**ប្រការ ១៨**.—

គណៈកម្មាធិការប្រតិបត្តិសមាគម ត្រូវការប្រជុំជ្រើសរើសបុគ្គលិកទទួលបន្ទុកផ្នែកនីមួយៗនៃកិច្ចការរបស់សមាគម។

**ប្រការ ១៩**.—

គណៈកម្មាធិការប្រតិបត្តិត្រូវរៀបចំមហាសន្និបាត ជាមួយនឹងសមាជិក-សមាជិកា ស.អ.ល.ក នឹងធ្វើ១ឆ្នាំម្តង ដើម្បីពិនិត្យ និងពិភាក្សាលើ របាយការណ៍លទ្ធផលការងារកន្លងមក របាយការណ៍ហិរញ្ញវត្ថុ និងលើកទិសដៅផែនការការងារសម្រាប់អនុវត្តបន្ត ។

**ប្រការ ២០**.—

ប្រធានប្រតិបត្តិ ស.អ.ល.ក អាចកោះអញ្ជើញប្រជុំវិសាមញ្ញក្នុងករណីចាំបាច់ ដើម្បីពិគ្រោះយោបល់លើកិច្ចការចាំបាច់ដែលជាប្រយោជន៍របស់ ស.អ.ល.ក។ ក្នុងករណីប្រធានអវត្តមាន អនុប្រធាន១រូប ឬ មន្ត្រីដែលចាត់តាំងដោយប្រធាន ត្រូវដឹកនាំប្រជុំជំនួសតាមការប្រគល់សិទ្ធិពីប្រធាន ។

## ជំពូកទី៤
## តួនាទី និងភារៈកិច្ច

**ប្រការ ២១.—**

គណៈកម្មាធិការចំពោះកិច្ច គឺត្រូវបង្កើតឡើង ដើម្បីជួយការពារផលប្រយោជន៍ស្របច្បាប់របស់សមាជិក-សមាជិកានៃសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា ។ សមាភាព គណៈកម្មាធិការចំពោះកិច្ច រួមមានប្រធាន១រូប អនុប្រធាន១រូប សមាជិក និងជំនួយការតាមការចាំបាច់ ។ គណៈកម្មាធិការចំពោះកិច្ច មានភារកិច្ចរួមដូចតទៅ ៖

- ជួយដោះស្រាយបញ្ហារួម និងបញ្ហាដោយឡែករបស់សមាជិក ស.អ.ល.ក (រាល់បណ្តឹងចូលមក គណៈកម្មាធិការខាងលើនេះ គឺយ៉ាងយូរ៥ថ្ងៃការងារ គណៈកម្មាធិការ ត្រូវធ្វើសកម្មភាពឆ្លើយតប នឹងបណ្តឹងទាំងនោះ ក្នុងករណីដោះស្រាយមិនចេញ ត្រូវបញ្ជូនករណីនោះ ទៅសុំការអន្តរាគមន៍ពីប្រធានសមាគម)។
- ផ្តល់ការប្រឹក្សាយោបល់លើបញ្ហាហិរញ្ញវត្ថុ
- ផ្តល់ប្រឹក្សាយោបល់ និង ជួយតវ៉ាលើបញ្ហាពន្ធដារ
- ផ្តល់ប្រឹក្សាយោបល់ និង ជួយតវ៉ាលើបញ្ហាច្បាប់លើវិស័យសំណង់ និងអចលនទ្រព្យ
- ផ្តល់ប្រឹក្សាយោបល់ និង ជួយសម្របសម្រួលលើបញ្ហានីតិវិធីរដ្ឋបាល
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនប្រធាន ស.អ.ល.ក ។

**ប្រការ ២២.—**

គណៈកម្មាធិការ អប់រំ បណ្តុះបណ្តាល និងស្រាវជ្រាវ មានភារកិច្ចដូចតទៅ ៖

- រៀបចំផែនការ និង គោលនយោបាយរបស់ ស.អ.ល.ក
- ចងក្រងទិន្នន័យ និង ព័ត៌មានទាក់ទងនឹងការអភិវឌ្ឍន៍លំនៅឋាន
- សិក្សាស្រាវជ្រាវរាល់ អំពីភាពស្របច្បាប់ និងមិនស្របច្បាប់ នៃការអភិវឌ្ឍន៍លំនៅឋាន
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាន ស.អ.ល.ក ។

**ប្រការ ២៣.—**

គណៈកម្មាធិការ ទំនាក់ទំនងជាតិ និងអន្តរជាតិ មានភារកិច្ចដូចតទៅ ៖

- ធ្វើការផ្សព្វផ្សាយ ព័ត៌មាន និងបញ្ជូនឯកសារនានារបស់សមាគមជូនសមាជិក
- ការរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសមាជិកទាំងអស់ និងដៃគូវិនិយោគរបស់សមាជិក
- ការធ្វើបដិសណ្ឋារកិច្ចជាមួយសមាជិក ទាំងក្នុងការិយាល័យ និងក្នុងកិច្ចប្រជុំផ្សេងៗ
- រៀបចំផែនការក្នុងការស្វែងរកសមាជិកថ្មីៗ ទាំងក្រុមហ៊ុនក្នុងស្រុក និងក្រៅស្រុក។

**ប្រការ ២៤**.–

គណៈកម្មាធិការ ហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ ៖

- ទទួលបន្ទុកការងារហិរញ្ញកិច្ចរបស់ ស.អ.ល.ក
- លើកគម្រោងផែនការថវិកាប្រចាំឆ្នាំ
- គ្រប់គ្រងចំណូលចំណាយ និងគ្រប់គ្រងទ្រព្យសម្បត្តិសម្ភារៈបរិក្ខាររបស់ ស.អ.ល.ក
- ពិនិត្យតារាងប្រាក់បៀវត្សន៍បុគ្គលិក រៀបចំសំណុំឯកសារ និងតម្លើងបៀវត្សន៍ជូនបុគ្គលិក
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាន ស.អ.ល.ក ។

**ប្រការ ២៥**.–

អគ្គលេខាធិការសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជាទទួលបន្ទុកៈ

- សម្របសម្រួលការងាររវាងផ្នែកនីមួយៗ
- ពិនិត្យ និងសិក្សាឯកសារនានាសម្រាប់ថ្នាក់ដឹកនាំ ស.អ.ល.ក
- គ្រប់គ្រងបុគ្គលិក និងសមាជិករបស់ ស.អ.ល.ក
- សម្របសម្រួលរាល់កិច្ចប្រជុំរបស់ ស.អ.ល.ក
- ពិនិត្យរបាយការណ៍ប្រចាំត្រីមាស ឆមាស និង របាយការណ៍ប្រចាំឆ្នាំ
- ទំនាក់ទំនងការងារជាមួយផ្នែកពាក់ព័ន្ធរដ្ឋ និង វិស័យឯកជន ដើម្បីបម្រើផលប្រយោជន៍សមាជិក ស.អ.ល.ក ។

**ប្រការ ២៦**.–

ផ្នែកច្បាប់ មានភារកិច្ចដូចជាៈ

- រៀបចំគោលការណ៍ នីតិវិធី និងឯកសាររដ្ឋបាលទាក់ទិននឹងផ្លូវច្បាប់
- ត្រួតពិនិត្យ និងវាយតម្លៃ ឯកសារគតិយុត្តនានារបស់សមាគម
- ការតាមដានបច្ចុប្បន្នភាពរបស់គោលការណ៍ ឬច្បាប់ផ្សេងៗរបស់ស្ថាប័នរដ្ឋ
- ចូលរួមដោះស្រាយ និង សម្របសម្រួលតាមនីតិវិធីច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ពេលដោះស្រាយវិវាទជូនសមាជិក។

**ប្រការ ២៧**.–

ផ្នែក រដ្ឋបាល និង លេខាធិការ មានភារកិច្ចដូចតទៅ ៖

- គ្រប់គ្រង ចាត់ចែង និង ធ្វើចរាចរណ៍លិខិតស្នាមផ្សេងៗ
- រៀបចំ សម្របសម្រួលរាល់កិច្ចប្រជុំរបស់ ស.អ.ល.ក
- ធ្វើរបាយការណ៍រាល់កិច្ចប្រជុំរបស់ ស.អ.ល.ក
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងារប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំជូន ស.អ.ល.ក
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាន ស.អ.ល.ក ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**ប្រការ ២៨.—**

បទបញ្ជាផ្ទៃក្នុងនេះ អាចកែប្រែបានល្គឹកណាមានការស្នើសុំពី ប្រធានគណៈកម្មាធិការប្រតិបត្តិ ឬ សមាជិក-សមាជិកា នៃ ស.អ.ល.ក ចំនួន ១/៣ ។

ការកែប្រែបទបញ្ជាផ្ទៃក្នុងនេះ ត្រូវសម្រេចដោយសំឡេងភាគច្រើនដាច់ខាត៥០ភាគរយបូក១ នៃ ចំនួនសមាជិក ស.អ.ល.ក ។

**ប្រការ ២៩.—**

រាល់បទប្បញ្ញត្តិទាំងឡាយណារបស់សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា ដែលមានខ្លឹមសារ ផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣០.—**

បទបញ្ជាផ្ទៃក្នុងរបស់សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា មានសុពលភាពគតិយុត្តចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ៕

*រាជធានីភ្នំពេញ ថ្ងៃទី 28 ខែ 12 ឆ្នាំ 2015*

**ជ.គណៈកម្មាធិការប្រតិបត្តិ**

**ប្រធាន**

**ឧកញ៉ា.លី_ហួរ**